សហព័ន្ធខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM FEDERATION**

**Asia - Australia - Europe - North America**

Office of the Chairman | ការិយាល័យលោកអធិបតី

N° 009 /KKF.CHM/13
Date :  11avril 2013

# សួស្តីឆ្នាំថ្មី!
## ម្សាញ់បញ្ចស័ក ព.ស. ២៥៥៧ - គ.ស. ២០១៣
### សូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ,
### សូមគោរពបង-ប្អូនរួមជាតិជាទីមេត្រី

ក្នុងឱកាសចូលឆ្នាំថ្មី **ម្សាញ់បញ្ចស័ក ព.ស. ២៥៥៧ - គ.ស. ២០១៣** តាងនាមសហព័ន្ធខ្មែរកម្ពុជាក្រោម ពិភព លោក ខ្ញុំព្រះករុណា-ខ្ញុំបាទ សូមធ្វើគារវកិច្ចគោរព និងជូនពរសេរីសួស្តីជ័យមង្គល់ចំពោះព្រះសង្ឃ បងប្អូន បុរស-ស្ត្រី, យុវជន-យុវតី ទាំងនៅក្នុងស្រុក,នៅកម្ពុជានិងនៅប្រទេសទី៣ ដែលបានបូជាជីវិត បូជាកម្លាំងកាយ-ចិត្ត-ថវិកា និងបញ្ញា ដើម្បីជាតិ សាសនា ក្នុងបុព្វហេតុសិទ្ធិ-សេរីភាព ឆ្ពោះទៅរកសិទ្ធិសំរេចវាសនាខ្លួនដោយខ្លួនឯង ឲ្យបានជួបប្រទះតែនិង ពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កំបីឃ្លៀងឃ្លាតឡើយ ។

សូម **ព្រះទេពធិតាព្រះនាម ទុង្សាទេវី បុត្រីទី១ នៃកបិលមហាព្រហ្ម** ដែលនិងយាងមកកាន់ដំណែងជា ទេវតា ឆ្នាំថ្មី ២០១៣ នេះ ប្រើឥទ្ធិពលជួយលើកទឹកចិត្តកូនខ្មែរឲ្យមានគំនិតជាតិនិយមនិងរួមសាមគ្គីគ្នាកំចាត់សត្រូវ អប្រិយរបស់ខ្មែរ ឲ្យ វិនាសអន្តរាយ ដើម្បីរកយុត្តិធម៌ និងសេចក្តីសុខសាន្តជូនប្រជាពលរដ្ឋខ្មែរ ។ បន្ថែមពីនេះទៅទៀតខ្ញុំ ក៏សូមវិញ្ញាណក្ខន្ធនៃ វីរបុរសខ្មែរមកសន្ថិតលើកូនខ្មែរគ្រប់រូបឲ្យមានសេចក្តីក្លាហាន មកចូលរួម តស៊ូរដោយសន្តិវិធីគ្រប់វិ ស័យជាមួយ សហព័ន្ធខ្មែរ កម្ពុជាក្រោម ដើម្បីកំចាត់អំពើរំលោភសិទ្ធិមនុស្ស និងរើសអើងជាតិសាស្ត្រ នៅកម្ពុជាក្រោម ។

ក្នុងវិស័យនេះ នៅឆ្នាំ ២០១៣ សហព័ន្ធខ្មែរកម្ពុជាក្រោម និងបន្តផែនការណ៍ឆ្នាំ ២០១២ ទៅទៀតក្នុងកម្មវិធីនយោបាយ ឆ្ពោះ ទៅកាន់មាតុភូមិ៍ តាមរយៈរចនាសម្ព័ន្ធជាមួយ ៖

- ស្ថាប័នអន្តរជាតិ មានអង្គការសហប្រជាជាតិ និងសភាអ៊ឺរុបជាដើម ដើម្បីសុំឲ្យស្ថាប័នទាំងនេះ បង្ខំឲ្យរដ្ឋអំណាច យួន គោរពសិទ្ធិយើងជាជនជាតិដើម ក្នុងក្របខ័ណ្ឌសិទ្ធិកូនក្មេង - សិទ្ធិស្ត្រី, សេរីភាពផ្នែកជំនឿ - ផ្នែកនិយាយ ស្តីនិងពត៌មាន ជាដើម ។ ល ។ ...
- ការងារនៅកម្ពុជា មានការតវ៉ាសុំឲ្យអង្គការសហប្រជាជាតិ ជួយរកផ្លូវដោះស្រាយជាមួយរដ្ឋាភិបាលកម្ពុជា សម្រួលឲ្យបង-ប្អូនខ្មែរក្រោមដែលបានភៀសខ្លួនមកកម្ពុជាដោយសារសោកនាដកម្មនៅ កម្ពុជាក្រោម ឲ្យមានលក្ខន្តិកៈសង្គមរសនៅបានដោយស្របច្បាប់, ... និង
- ការងារនៅកម្ពុជាក្រោម ដើម្បីអបរំបង-ប្អូនខ្មែរក្រោមឲ្យស្គាល់នូវសិទ្ធិរបស់ខ្លួន និងដើម្បីបញ្ឈប់នូវរាល់អំពើ រំ លោភ សិទ្ធិមនុស្សពីសំណាក់រដ្ឋអំណាចយួន ដែលកំពុងគំរាមកំហែងដល់ជីវិតប្រចាំថ្ងៃទូទាំងកម្ពុជាក្រោម មាន ព្រះពុទ្ធសាសនាថេរវាទ និងការរស់នៅរបស់បង-ប្អូនរួមជាតិនៅទីនោះ ជាពិសេស ឥឡូវនេះកំពុងមានការកំរាមកំហែង យ៉ាងខ្លាំងពីសំនាក់រដ្ឋអំណាចយួនលើព្រះសង្ឃនៅវត្ត ព្រៃជាប់ ខេត្តឃ្លាំង ដើម្បីផ្សឹកលោក និងបណ្តេញ លោកចេញពីវត្តដោយមិនសំហេតុផល ។

**KKF** - P.O. Box 0193, Pennsauken - NJ08110, USA • Tel : (818) 448-4196 • Fax : (856) 583-1503
http://www.khmerkrom.net / www.khmerkrom.org • Email : vien.thach@khmerkrom.org

ក្នុងមូលហេតុទាំងអស់ខាងលើនេះ សហព័ន្ធខ្មែរកម្ពុជាក្រោម សូមអំពាវនាវដល់បង-ប្អូនរួមជាតិមក ចូលរួមធ្វើសហការជា មួយគ្នា  ដើម្បីឲ្យការតស៊ូរបស់យើងមានដំណើរបានឆាប់ដល់ត្រើយ ។ សូមអរព្រះគុណ និងអរគុណទុកជាមុន ។

ជាទីបញ្ចប់ សូម **ព្រះទេពធិតាព្រះនាម ទុង្សាទេវី បុត្រីទី១ នៃកបិលមហាព្រហ្ម** ជាទេវតាឆ្នាំថ្មីមេត្តាជួយ ប្រសិទ្ធិពរជ័យ ឲ្យគោលបំណងរបស់យើងខ្ញុំទាំងអស់ខាងលើនេះបានសំរេចដូចបំណងកំបីអាក់ខានឡើយ ។

ធ្វើនៅប៉ារិស, ថ្ងៃទី ១១មេសា ឆ្នាំ២០១៣
អធិបតី សហព័ន្ធខ្មែរកម្ពុជាក្រោម,
លោក ថាច់-វៀន

**KKF** - P.O. Box 0193, Pennsauken - NJ08110, USA • Tel : (818) 448-4196 • Fax : (856) 583-1503
http://www.khmerkrom.net / www.khmerkrom.org • Email : vien.thach@khmerkrom.org